# តើអ្វីទៅជាបញ្ហាការប្រើប្រាស់សារធាតុញៀន?

បញ្ហាការប្រើប្រាស់សារធាតុញៀន ត្រូវបានគេស្គាល់ផងដែរ ថាជាការញៀន គឺជាស្ថានភាពវេជ្ជសាស្ត្រមួយ ដែលកើតឡើងនៅពេលដែលការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនជាប្រចាំ ដែលបណ្តាលឱ្យមានគ្រោះថ្នាក់និងបំផ្លាញខ្លួនឯង។ ដូចទៅនឹងស្ថានភាពវេជ្ជសាស្ត្រ ផ្សេងទៀត វាអាចព្យាបាលបាន។



## តើធ្វើដូចម្តេចដើម្បីទទួលបានជំនួយ

- ទូរស័ព្ទមកយើងដោយមិនគិតថ្លៃតាមលេខ **1(844) 804-7500 ។** ខ្សែទូរស័ព្ទជំនួយអំពីសេវាកម្មបញ្ហាប្រើប្រាស់សារធាតុញៀន 24/7។
- សូមចូលទៅកាន់ **SUDHelpLA.org** សម្រាប់បញ្ជីរាយនាមអ្នកផ្តល់សេវា លើអនឡាញលម្អិតដែលមានជាភាសាផ្សេងៗ។
- សូមចូលទៅកាន់ **RecoverLA.org** សម្រាប់ធនធានអ្នកផ្តល់សេវា តាមទូរស័ព្ទចល័ត។

## តើសិទ្ធិរបស់ខ្ញុំមានអ្វីខ្លះ?

ប្រសិនបើអ្នកគិតថាអ្នកមានសិទ្ធិទទួលបាន ប៉ុន្តែត្រូវបានបដិសេធ សេវាត្រូវបានបដិសេធ ឬមានគិតថ្លៃណាមួយ សូមទូរស័ព្ទទៅ Los Angeles County Substance Abuse Prevention and Control (SAPC) តាមលេខ 1(888) 742-7900 ហើយចុចលេខ 7 ដើម្បីធ្វើការតវ៉ា បណ្តឹង។ ដើម្បីស្វែងយល់បន្ថែមអំពីសិទ្ធិរបស់អ្នក សូមចូលទៅកាន់

**http://publichealth.lacounty.gov/sapc/PatientPublic.htm**

- **ជំនួយ និងសេវាកម្មបឋម** រួមមានដូចជា ឯកសារបោះពុម្ពអក្សរធំ និងទម្រង់ផ្សេងៗ អ្នកអាច ទទួលបានដោយមិនគិតថ្លៃតាមការស្នើសុំ។
- **កំណត់សម្គាល់៖** ប្រសិនបើអ្នកនិយាយភាសាផ្សេង សេវាកម្មជំនួយភាសា នឹងផ្តល់ជូនមិនគិតថ្លៃសម្រាប់អ្នក។ SAPC អនុលោមតាមច្បាប់សិទ្ធិស៊ីវិលរបស់សហព័ន្ធ និងរដ្ឋដែលបានដាក់ប្រើប្រាស់ និងមិនរើសអើងលើមូលដ្ឋាននៃជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិ ប្រភពដើម អាយុ ពិការភាព ឬភេទ ឬក្នុងលក្ខណៈណាមួយលើមូលដ្ឋាន ទិសដៅភេទ។

  សូមទូរស័ព្ទទៅលេខ 1(844) 804-7500 (TTY: California Relay ៧១១)។

# តើបញ្ហាគ្រឿងស្រវឹង ឬគ្រឿងញៀនប៉ះពាល់ដល់អ្នកមែនទេ?

## ការស្តារសុខភាពឡើងវិញ

SUBSTANCE ABUSE SERVICE HELPLINE

24/7 1.844.804.7500



SAPC Substance Abuse Prevention and Control

County of Los Angeles Public Health

SAPC Substance Abuse Prevention and Control

County of Los Angeles Public Health

# 95%

## នៃអ្នកដែលមាន បញ្ហា ប្រើប្រាស់ សារធាតុញៀន មិនដឹងពីរបៀបទទួល ជំនួយ ឬមិនមានអារម្មណ៍ ថា ពួកគេត្រូវការ ការ ព្យាបាល[1]។



[1] National Survey on Drug Use and Health (NSDUH)

## តើបញ្ហានេះកើតឡើងចំពោះអ្នកទេ?

- ☐ តើអ្នកមានអារម្មណ៍ថាការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន របស់អ្នកកំពុងរារាំងអ្នក ឬប៉ះពាល់ដល់ទំនាក់ទំនង ការងារ  ការសិក្សា ឬជីវិតទូទៅរបស់អ្នកទេ?
- ☐ តើអ្នកកំពុងប្រើគ្រឿងស្រវឹង ឬថ្នាំញៀនច្រើនជាងការចង់ ឬពិបាកក្នុងការកាត់បន្ថយ ឬគ្រប់គ្រងការប្រើប្រាស់ សារធាតុញៀនមែនទេ?
- ☐ តើអ្នកធ្លាប់ត្រូវបានគេប្រាប់ថាអ្នកគួរឈប់ពិសារគ្រឿងស្រវឹង ឬប្រើប្រាស់គ្រឿងញៀន ឬថាអ្នកគួរប្រើប្រាស់វាតិចជាងនេះ?
- ☐ តើអ្នកមានអារម្មណ៍ថាឈឺ ឬមិនស្រួលខ្លួននៅពេលឈប់ ប្រើគ្រឿងស្រវឹង ឬគ្រឿងញៀនដែរទេ?

**ប្រសិនបើអ្នកបានធីកប្រអប់ណាមួយខាងលើ យើងអាចជួយអ្នកបាន!**

## SUBSTANCE ABUSE SERVICE HELPLINE

24/7 **1.844.804.7500**

### ទូរស័ព្ទទៅខ្សែទូរស័ព្ទឥតគិតថ្លៃបានគ្រប់ពេលវេលា!

## តើមានសេវាកម្មអ្វីខ្លះ?[5]

- ✓ សេវាអន្តរាគមន៍បឋម
- ✓ ការព្យាបាលអ្នកជំងឺមិនស្នាក់នៅមន្ទីរពេទ្យ
- ✓ ការព្យាបាលអ្នកជំងឺមិនស្នាក់នៅមន្ទីរពេទ្យធ្ងន់ធ្ងរ
- ✓ ការសម្របសម្រួលការថែទាំ
- ✓ ឱសថសម្រាប់ព្យាបាលបញ្ហាសារធាតុញៀន
- ✓ ការគ្រប់គ្រងការផ្តាច់សារធាតុញៀន (ការបន្សាបជាតិពុល)
- ✓ ការព្យាបាលនៅផ្ទះ
- ✓ កម្មវិធីព្យាបាលសារធាតុអាភៀន
- ✓ សេវាស្តារនីតិសម្បទា
- ✓ សេវាផ្តល់កន្លែងសម្រាកព្យាបាល (Recovery Bridge Housing)[6]

## តើមានអ្វីកើតឡើងនៅពេលខ្ញុំទូរស័ព្ទ?

- យើងមានក្រុមការងារ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃ ក្នុង មួយសប្តាហ៍ ដើម្បីឆ្លើយតបការហៅទូរស័ព្ទរបស់អ្នក។
- យើងនឹងសួរអ្នកនូវសំណួរអំពីគ្រឿងស្រវឹង និង/ឬការប្រើប្រាស់គ្រឿងញៀនរបស់អ្នក ដើម្បីជួយអ្នកក្នុងការសម្រេចចិត្តថាតើអ្នកត្រូវការ ការព្យាបាលឬទេ។[2]
- យើងនឹងជួយអ្នកស្វែងយល់ពីជម្រើសរបស់អ្នក និងស្វែងរក អ្នកផ្តល់សេវាដែលបំពេញតម្រូវការជាក់លាក់របស់អ្នក។[2]
- យើងនឹងរក្សាព័ត៌មានរបស់អ្នកឱ្យមានសុវត្ថិភាព និងសម្ងាត់។

## តើខ្ញុំមានសិទ្ធិទទួលបានទេ?

យុវជន និងមនុស្សពេញវ័យ គ្រប់ស្ថានភាពអន្តោប្រវេសន៍ទាំងអស់[3] អាច ទទួលបានសេវាព្យាបាលការប្រើប្រាស់សារធាតុញៀន **ឥតគិតថ្លៃ**[4] នៅគ្រប់ អ្នកផ្តល់សេវាទាំងអស់នៅក្នុងបណ្តាញ ប្រសិនបើអ្នកបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- អ្នកគឺជាប្រជាជនរស់នៅខោនធី Los Angeles ហើយអ្នក មានសិទ្ធិទទួលបាន Medi-Cal[4] ឬ ខោនធីទួលបានកម្មវិធីមូលនិធិដែលបានជ្រើសរើសផ្សេងទៀត។ យុវជន និងមនុស្សពេញវ័យដែលត្រូវការកា ព្យាបាលបន្ទាន់ អាចទទួលបានជំនួយក្នុងការថែទាំផ្នែកវេជ្ជសាស្ត្រ ប្រសិនបើមិនមានលទ្ធភាពបង់ថ្លៃ សេវាថែទាំ។

[2] សេវាកម្មមានដើម្បីបំពេញតាមតម្រូវការភាសា វប្បធម៌ ទីតាំង និងតម្រូវការសេវាកម្មតាមការចង់បានផ្សេងទៀត។ ក្នុងករណីមួយចំនួន មាតាបិតា/អាណាព្យាបាលក៏អាចធ្វើការហៅទូរស័ព្ទក្នុងនាមអនីតិជនដែលត្រូវការជំនួយផងដែរ។

[3] ស្ថានភាពអន្តោប្រវេសន៍មិនត្រូវបានចែករំលែក និងត្រូវបានរក្សាទុកជាសម្ងាត់។

[4] សហចំណាយអាចត្រូវបានទាមទារសម្រាប់បុគ្គលដែលមានសិទ្ធិ Medi-Cal មួយចំនួន។

[5] សេវាកម្ម និងការព្យាបាលមួយចំនួនទាមទារសេចក្តីអនុញ្ញាតជាមុនសម្រាប់យុវជន និងមនុស្សពេញវ័យដែលមានសិទ្ធិ។

[6] សេវា Recovery Bridge Housing គឺសម្រាប់បុគ្គលដែលមានអាយុ ១៨ ឆ្នាំឡើងទៅ។